# សង្គមស៊ីវិល អ្នកសារព័ត៌មាន ចង់ឃើញការគោរពតម្លៃស្ត្រីបន្ទាប់ពីមានការវាយប្រហារលើអ្នកសារព័ត៌មានស្ត្រីVOD។

មន្ត្រីសង្គមស៊ីវិល អ្នកវិភាគ និងអ្នកសារព័ត៌មានមួយចំនួនចង់ឃើញការផ្តល់តម្លៃស្ត្រីក្រោយអ្នកសារព័ត៌មានVODម្នាក់ រងការវាយប្រហារពីអ្នកលេងបណ្តាញសង្គមហ្វេសបុកម្នាក់ដែលជាអ្នកគាំទ្រគណបក្សប្រជាជនកម្ពុជា គឺ លោក ផែង វណ្ណៈ។ ពួកគេចាត់ទុកពាក្យសម្តីលោក ផែង វណ្ណៈ ដើរផ្ទុយពីឆន្ទៈរបស់រដ្ឋាភិបាលដែលតែងលើកកម្ពស់សេចក្តីថ្លៃថ្នូររបស់ស្ត្រី។ លោក ផែង វណ្ណៈ នៅថ្ងៃទី១១ខែកុម្ភៈបានសសេរសំណេររិះគន់ស្ត្រីអ្នកសារព័ត៌មានVOD ជាមួយនឹងខ្លឹមសារបន្ទាបតម្លៃ បន្ទាប់ពីនាងចេញ

ផ្សាយអត្ថបទក្រោមចំណងជើងថា «មន្ត្រីរដ្ឋាភិបាលថា ការដែលលោក ហ៊ុន ម៉ាណែត ដើរតួនាទីជំនួសឪពុកក្នុងការផ្តល់ជំនួយឱ្យតួកគី មិនមែនជារឿងខុសឆ្គង»។

លោកស្រី ចក សុភាព នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាលើកឡើងថា រឿងផ្សាយព័ត៌មានពិតឬមិនពិត បានមកពីប្រភពមិនច្បាស់ឬច្បាស់ ទុកពេលវេលាឱ្យស្ថាប័នពាក់ព័ន្ធដោះស្រាយទៅតាមវិជ្ជាជីវៈរបស់ខ្លួនទៅ។ តែសម្រាប់លោក ផៃង វណ្ណៈ វាយប្រហារលើស្ត្រីជាអ្នកសារព័ត៌មានបានឆ្លុះបញ្ចាំងពីកម្រិតគុណធម៌របស់លោក។ បើតាមលោកស្រី ចក សុភាព ក្នុងនាមជាបុគ្គលសាធារណៈលោក ផៃង វណ្ណៈ គួរប្រកាន់សីលធម៌ ហើយលោកគួរសុំទោសជាសាធារណៈដល់ស្ត្រីអ្នកសារព័ត៌មានរូបនេះ និងបញ្ឈប់នូវឥរិយាបទដែលផ្ទុយពីឆន្ទៈរបស់រដ្ឋាភិបាលដែលតែងលើកកម្ពស់សេចក្តីថ្លៃថ្នូររបស់ស្ត្រី។ នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សរូបនេះចង់ឃើញស្ថាប័នពាក់ព័ន្ធមានចំណាត់ការលើទង្វើនេះ ដើម្បីបង្ហាញពីសេចក្តីថ្លៃថ្នូរនិងសីលធម៌សង្គម។

ក្នុងពេលជាមួយគ្នានេះដែរ លោកបណ្ឌិត សេង សារី អ្នកវិភាគនយោបាយ លោកបណ្ឌិត មាស នី អ្នកស្រាវជ្រាវសង្គម បណ្ឌិត ឡៅ ម៉ុងហៃ ជាដើមក៏បានសម្តែងការហួសចិត្តចំពោះសំណេរវាយប្រហាររបស់របស់លោក ផៃង វណ្ណៈ ដែលជាអ្នកប្រើប្រាស់បណ្តាញសង្គមដ៏លេចធ្លោនិងជាអ្នកគាំទ្រគណបក្សប្រជាជនមកលើស្ត្រីអ្នកសារព័ត៌មានVODរូបនេះ។

បើតាមបណ្ឌិត សេង សារី  ការចាត់ការជនពាល និងជនវិកលចរិត ដែលសង្ងំក្នុងវិស័យព័ត៌មាន គឺអាចយកមកធ្វើជាគោលនយោបាយសម្រាប់ការប្រកួតប្រជែងការបោះឆ្នោតឆ្នាំ ២០២៣បានយ៉ាងមានប្រសិទ្ធ។ភ្លាមៗបន្ទាប់ពីចេញផ្សាយសំណេរនេះលោក ផៃង វណ្ណៈ ក៏បានចោទសួរទៅកាន់លោក សេង សារី វិញថា បណ្ឌិត សេង សារី គាំទ្រ VOD ដែលបំពុលព័ត៌មាន  ឬ លោកបណ្ឌិតជាជនបំពុលសង្គមដែរ ?

លោក ណុប វី នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខាមបូចា)បង្ហាញការសោកស្តាយចំពោះការបង្ហាញ ក៏ដូចជាការបញ្ចេញមតិដែលធ្វើឲ្យមានការស្អប់ខ្ពើមនៅក្នុងសង្គម។ មតិរបស់លោកផៃង វណ្ណៈ បានបង្ហាញនូវការប្រមាថដល់ស្ត្រីដែលមានសេចក្តីក្លាហាន

ចូលរួមនៅក្នុងការផ្តល់ព័ត៌មានក្នុងសង្គម ហើយការបញ្ចេញមតិនេះជាការប្រមាថនឹងជាការចូលរួមធ្វើឲ្យមានការបែកបាក់ក្នុងសង្គម និងមិនបង្ហាញពីកាតព្វកិច្ចពលរដ្ឋល្អឡើយ។ ដូច្នេះលោក ផេង វណ្ណៈគួរសុំទោសដល់ស្ត្រីដែលលោកបានប្រមាថនេះ។  នេះបើតាមលោក ណុប វី។

ចំណែកអ្នកនាង ឡុង គឹមម៉ារីតា ជាអ្នកសារព័ត៌មានម្នាក់បានចោទសួរថា ហេតុអ្វីអ្នកកាសែតវិជ្ជាជីវៈ ត្រូវប្រឈមនឹងការតិះដៀល និងគំនាប។ ជាចាស់ជាទុំ គួរប្រើសម្តីឲ្យក្មេងគោរព មិនមែនប្រើអំណាច អាងចាស់ដើរជេគេ ហើយពោលថា ជាពាក្យប្រដៅនោះទេ។

ទន្ទឹមគ្នានេះកញ្ញា សុវណ្ណ ស្រីពេជ្រ ជាអ្នកសារព័ត៌មានមួយរូបទៀតបានបង្ហាញក្តីព្រួយបារម្ភថា ពីមួយថ្ងៃទៅមួយថ្ងៃ អាជីពជាអ្នកសារព័ត៌មានគឺមានសម្ពាធមួយកម្រិតទៅហើយ តែគួរឱ្យខ្ពើមរអើមទៅទៀតនោះ គឺការប្រមាថមកលើអ្នកសារព័ត៌មានស្ត្រី ការលាបពណ៌ ការប្រើសម្តីអសុរៈ មិនឱ្យតម្លៃ ទម្រង់វាយប្រហារជាសាធារណៈស្តែងៗតែម្តង។ បើតាមកញ្ញា សុវណ្ណ ស្រីពេជ្រ ចង់ឃើញស្ថាប័នពាក់ព័ន្ធ អន្តរាគមន៍ចំពោះ លោក ផេង វណ្ណៈ ដែលលោកប្រើពាក្យពេចន៍ចោទប្រកាន់ និងប្រមាថយ៉ាងធ្ងន់ធ្ងរទៅលើស្ត្រី ផ្ទុយពីអ្វីដែលរដ្ឋាភិបាល និងសង្គមកំពុងលើកតម្កើងស្ត្រី៕